# ចតុប្បោសថជាតក



*ចតុប្បោសថជាតកនេះ មានពាក្យថា* **យោ កោបនេយ្យេ** *ជាដើម នឹងមានជាក់ច្បាស់ក្នុង***បុណ្ណកជាតក** *( វិធុរជាតក បិដកលេខ ៦៣ ទំព័រ ៣៣ ) ។*

*ខាងក្រោមនេះជាសេចក្តីដែលមានមកក្នុងព្រះបាលី ៖*

( ព្រះចានវរុណនាគរាជពោលថា )

យោ កោបនេយ្យេ ន ករោតិ កោបំ, ន កុជ្ឈតិ សប្បុរិសោ កទាចិ;
កុទ្ធោបិ សោ នាវិករោតិ កោបំ, តំ វេ នរំ សមណមាហុ លោកេ ។

*បុគ្គលណាជាសប្បុរស មិនធ្វើនូវសេចក្ដីក្រោធ ក្នុងបុគ្គលគួរក្រោធ និងមិនក្រោធ ក្នុងកាលណាមួយ បុគ្គលជាសប្បុរសនោះ បើទុកជាក្រោធ ក៏មិនធ្វើសេចក្ដីក្រោធឲ្យប្រាកដ បណ្ឌិតទាំងឡាយ ហៅជននោះឯងថាជាសមណៈ ក្នុងលោក ។*

(សុវណ្ណរាជពោលថា)

ឧទ្ធរេ យោ សហតេ ជិឃច្ឆំ, ទន្តោ តបស្សី មិតបានភោជនោ;
អាហារហេតុ ន ករោតិ បាបំ, តំ វេ នរំ សមណមាហុ លោកេ ។

*ជនណា មានពោះធូរ អត់ទ្រាំនូវសេចក្ដីស្រេកឃ្លានបាន ទូន្មាននូវឥន្ទ្រិយ ជាអ្នកមានតបធម៌ មានទឹក និងភោជនល្មមប្រមាណ មិនធ្វើនូវបាប ព្រោះហេតុនៃអាហារឡើយ បណ្ឌិតទាំងឡាយ ហៅជននោះថាជាសមណៈ ក្នុងលោក ។*

(សក្កទេវរាជ ពោលថា)

ខិឌ្ឌំ រតឹ វិប្បជហិត្វាន សព្វំ, ន ចាលិកំ ភាសសិ កិញ្ចិ លោកេ;
វិភូសដ្ឋានា វិរតោ មេថុនស្មា, តំ វេ នរំ សមណមាហុ លោកេ ។

*ជនណា លះបង់នូវល្បែង (ដោយកាយនិងវាចា) និងសេចក្ដីត្រេកអរ (ក្នុងកាមគុណ) ទាំងពួង ទាំងមិនពោលនូវពាក្យឡេះឡោះ តិចតួចក្នុងលោក វៀរចាកហេតុជាទីតាំងនៃការស្អិតស្អាង និងមេថុនធម្ម បណ្ឌិតទាំងឡាយហៅជននោះឯង ថាជាសមណៈ ក្នុងលោក ។*

(ព្រះចាឧជនញ្ជ័យ ពោលថា)

បរិគ្គហំ លោភធម្មញ្ច សព្វំ, យោ វេ បរិញ្ញាយ បរិច្ចជេតិ;
ទន្តំ ឋិតត្តំ អមមំ និរាសំ, តំ វេ នរំ សមណមាហុ លោកេ ។

*ជនណា កំណត់ដឹង ហើយលះបង់នូវទ្រព្យសម្បត្តិផង លោកៈទាំងពួងផង បណ្ឌិតទាំងឡាយ ហៅជនដែលមានខ្លួនទូន្មាន មានសភាពខ្ជាប់ខ្ជួន មិនមានសេចក្តីប្រកាន់ថា អញ មិនមានសេចក្តីប្រាថ្នានោះឯង ថាជាសមណៈ ក្នុងលោក ។*

(ព្រះរាជាទាំង ៤ ព្រះអង្គនោះ ត្រាស់សួរថា)

បុច្ឆាម កត្តារមនោមបញ្ញំ, កថាសុ នោ វិគ្គហោ អត្ថិ ជាតោ;
ឆិន្ទជ្ជ កង្ខំ វិចិកិច្ឆិតានិ, តទជ្ជ កង្ខំ វិតរេមុ សព្វេ ។

*ម្នាលអ្នកមានប្រាជ្ញាមិនថោកថយ យើងទាំងឡាយ សូមសួរចំពោះអ្នក ជាអ្នកធ្វើ (នូវហេតុដែលគួរធ្វើ) ការជជែកចំពោះពាក្យទាំងឡាយ កើតមានដល់យើង សូមអ្នកកាត់នូវសេចក្តីងឿងឆ្ងល់ និងសេចក្តីសង្ស័យចេញ ក្នុងថ្ងៃនេះ យើងទាំងអស់គ្នា គប្បីឆ្លងនូវសេចក្តីសង្ស័យនោះ ក្នុងថ្ងៃនេះ ។*

(វិធុរបណ្ឌិតពោធិសត្វ ពោលថា)

យេ បណ្ឌិតា អត្ថទសា ភវន្តិ, ភាសន្តិ តេ យោនិសោ តត្ថ កាលេ;
កថំ នុ កថានំ អភាសិតានំ, អត្ថំ នយេយ្យុំ កុសលា ជនិន្ទា ។

*បណ្ឌិតណា ជាអ្នកយល់សេចក្តី បណ្ឌិតនោះ រមែងពោលដោយឧបាយនៃប្រាជ្ញា ក្នុងកាលគួរ ក្នុងពាក្យជជែកនោះ បពិត្រព្រះអង្គជាធំជាងជនទាំងឡាយ ពួកជនអ្នកឈ្លាស គប្បីយល់នូវសេចក្តីនៃពាក្យពោលដែលគេមិនទាន់និយាយ ដោយប្រការដូចម្តេចបាន ។*

កថំ ហវេ ភាសតិ នាគរាជា, គរុឡោ បន វេនតេយ្យោ កិមាហ;
គន្ធព្វរាជា បន កិំ វទេសិ, កថំ បន កុរូនំ រាជសេដ្ឋោ ។

*ស្តេចនាគ ពោលដូចម្តេច ស្តេចគ្រុឌវេនតេយ្យ ពោលដូចម្តេច ស្តេចគន្ធព្វ (ព្រះឥន្ទ) ពោលដូចម្តេច ស្តេចដ៏ប្រសើររបស់អ្នកដែនកុរុ ពោលដូចម្តេច ។*

(ព្រះរាជាទាំងឡាយនោះ ឆ្លើយថា)

ខន្តិំ ហវេ ភាសតិ នាគរាជា, អប្បាហារំ គរុឡោ វេនតេយ្យោ;
គន្ធព្វរាជា រតិវិប្បហានំ, អកិញ្ចនំ កុរុរាជសេដ្ឋោ ។

*ស្តេចនាគ ពោលចំពោះខន្តិធម៌តែម្យ៉ាង ស្តេចគ្រុឌវេនតេយ្យ ពោលចំពោះអាហារតិច ស្តេចគន្ធព្វ ពោលចំពោះការលះបង់សេចក្តីត្រេកអរ ស្តេចដ៏ប្រសើររបស់អ្នកដែនកុរុ ពោលចំពោះការមិនមានកង្វល់ ។*

(ព្រះវិធុរពោធិសត្វ ពោលថា)

សព្ពានិ ឯតានិ សុភាសិតានិ, ន ហេត្ថ ទុព្ភាសិតមត្ថិ កិញ្ចិ;
យស្មិញ្ច ឯតានិ បតិដ្ឋិតានិ, អរាវ នាភ្យា សុសមោហិតានិ;
ចតុព្ភិ ធម្មេហិ សមង្គិភូតំ, តំ វេ នរំ សមណមាហុ លោកេ ។

*ពាក្យទាំងអស់នេះ ជាសុភាសិត ពាក្យជាទុព្ភាសិត សូម្បីបន្តិចបន្តួច ក៏មិនមាន ក្នុងប្រស្នានេះទេ ម្យ៉ាងទៀត ពាក្យទាំងនេះ តាំងនៅស៊ប់ ប្រជុំចុះដោយល្អ ក្នុងបុគ្គលណា ដូចជាកាំរទេះ ដែលគេបញ្ចុះស៊ប់ក្នុងដុំ បណ្ឌិតទាំងឡាយ ហៅបុគ្គលដែលព្រមព្រៀង ដោយធម៌ ៤ យ៉ាងនោះឯង ថាជាសមណៈ ក្នុងលោក ។*

(ព្រះរាជាទាំង ៤ ព្រះអង្គពោលថា)

តុវញ្ហិ សេដ្ឋោ ត្វមនុត្តរោសិ, ត្វំ ធម្មគូ ធម្មវិទូ សុមេធោ;
បញ្ញាយ បញ្ហំ សមធិគ្គហេត្វា, អច្ឆេច្ឆិ ធីរោ វិចិកិច្ឆិតានិ;
អច្ឆេច្ឆិ កង្ខំ វិចិកិច្ឆិតានិ, ចុន្ទោ យថា នាគទន្តំ ខរេន ។

អ្នកជាបុគ្គលប្រសើរ អ្នកជាបុគ្គលមិនមានអ្នកណាវិសេសជាង អ្នកជាបុគ្គលដល់នូវត្រើយនៃធម៌ ចេះដឹងនូវធម៌ មានយោបល់ដ៏ល្អ កំណត់ដឹងនូវប្រស្នាដោយប្រាជ្ញា អ្នកជាអ្នកប្រាជ្ញ បានផ្តាច់សេចក្តីសង្ស័យចេញហើយ អ្នកបានកាត់នូវសេចក្តីសង្ស័យ និងសេចក្តីងឿងឆ្ងល់ ដូចជាគេកាត់នូវភ្លុកនៃដំរី ដោយរណារ ។

(សក្កទេវរាជ ពោលថា)

ឩលុប្បលាភំ វិមលំ អនគ្ឃំ, វត្ថំ ឥទំ ធូមសមានវណ្ណំ;
បញ្ហស្ស វេយ្យាករណេន តុដ្ឋោ, ទទាមិ តេ ធម្មប្ជាយ ធីរ ។

បពិត្រអ្នកប្រាជ្ញ ខ្ញុំត្រេកអរនឹងការដោះនូវប្រស្នា ហើយជូនសំពត់នេះ មានពន្លឺដូចផ្កាឧប្បលខៀវ មិនមានមន្ទិល ជាសំពត់កាត់ថ្លៃមិនបាន មានពណ៌ស្មើដោយផ្សែង ដើម្បីបូជានូវធម៌របស់អ្នក ។

(សុបណ្ណរាជពោលថា)

សុវណ្ណមាលំ សតបត្តផុល្លិតំ, សកេសរំ រត្នសហស្សមណ្ឌិតំ;
បញ្ហស្ស វេយ្យាករណេន តុដ្ឋោ, ទទាមិ តេ ធម្មប្ជាយ ធីរ ។

បពិត្រអ្នកប្រាជ្ញ ខ្ញុំត្រេកអរនឹងការដោះនូវប្រស្នា ហើយជូននូវកម្រងផ្កាមាស ដែលរីកសំពោង ដោយត្របកច្រើនស្រទាប់ ប្រកបដោយលំអង ដ៏ប្រដាប់ដោយកែវដ៏ច្រើន ដើម្បីបូជានូវធម៌របស់អ្នក ។

(វរុណនាគរាជពោលថា)

មណឹ អនគ្ឃំ រុចិរំ បភស្សរំ, កណ្ឋាវសត្តំ មណិភូសិតំ មេ;
បញ្ហស្ស វេយ្យាករណេន តុដ្ឋោ, ទទាមិ តេ ធម្មប្ជាយ ធីរ ។

*បពិត្រអ្នកប្រាជ្ញ ខ្ញុំត្រេកអរនឹងការដោះស្រាយនូវប្រស្នា ហើយជូននូវកែវមណី ដែលកាត់ថ្លៃមិនបាន ជាកែវដ៏រុងរឿង មានពន្លឺផ្ទេក ៗ សម្រាប់ពាក់ព្ធដ៏ក ដែលស្អិតស្អាងដោយកែវមណី ដើម្បីបូជានូវធម៌របស់អ្នក ។*

(ព្រះបាទធនញ្ជ័យពោលថា)

គវំ សហស្សំ ឧសភញ្ច នាគំ, អាជញ្ញយុត្តេ ច រថេ ទស ឥមេ;
បញ្ហស្ស វេយ្យាករណេន តុដ្ឋោ, ទទាមិ តេ គាមវរានិ សោឡស ។

*ខ្ញុំត្រេកអរនឹងការដោះស្រាយនូវប្រស្នា ហើយជូននូវគោមួយពាន់ ទាំងគោឧសភៈផង ដំរីផង រថ ១០ ដែលទឹមដោយសេះអាជានេយ្យនេះផង ស្រុកសួយ ១៦ ផង ដល់អ្នក ។*

(អភិសម្ពុទ្ធគាថា)

សារិបុត្តោ តទា នាគោ, សុបណ្ណោ បន កោលិតោ;
គន្ធព្វរាជា អនុរុទ្ធោ, រាជា អានន្ទ បណ្ឌិតោ;
វិធុរោ ពោធិសត្តោ ច, ឯវំ ធារេថ ជាតកំ ។

*អ្នកទាំងឡាយ ចូរចាំទុកនូវជាតក យ៉ាងនេះថា ស្តេចនាគក្នុងកាលណោះ បានមកជាព្រះសារីបុត្ត ស្តេចគ្រុឌ បានមកជាកោលិតភិក្ខុ (មោគ្គល្លាន) ស្តេចគន្ធព្វ បានមកព្រះអនុរុទ្ធ ព្រះបាទធនញ្ជ័យបានមកជាអានន្ទបណ្ឌិត វិធុរបណ្ឌិត គឺតថាគត ។*

*ចប់ ចតុប្បោសថជាតក ៕*

*(ជាតកដ្ឋកថា សុត្តន្តបិដក ខុទ្ទកនិកាយ ជាតក ទសកនិបាត បិដកលេខ ៥៩ ទំព័រ ១៦៧)*

*ដោយ ស.ដ.វ.ថ.*